ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា
គណៈកម្មាធិការលទ្ធកម្ម
លេខៈ ១១៧៤....PC. អក

**សេចក្តីជូនដំណឹងលើកទី២**
**ស្តីពី**
**ការងារចាក់ជើងគ្រឹះបង្គោលដែលមានទឹកលិច និងជីកប់គ្រឹះបង្គោលចំនួន 06 បង្គោលខ្សែបញ្ជូនអនុស្ថានីយទី២ ទៅអនុស្ថានីយទី៧ ជូននាយកដ្ឋានបញ្ជូនអគ្គិសនី**

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថាៈអគ្គិសនីកម្ពុជានឹងដាក់ឲ្យពិគ្រោះថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកទទួលការអញ្ជើញចូលរួមពិគ្រោះថ្លៃស្តីពី ការងារចាក់ជើងគ្រឹះបង្គោលដែលមានទឹកលិច និងជីកប់គ្រឹះបង្គោលចំនួន 06 បង្គោលខ្សែបញ្ជូនអនុស្ថានីយទី២ ទៅអនុស្ថានីយទី៧ ជូននាយកដ្ឋានបញ្ជូនអគ្គិសនី។

អគ្គិសនីកម្ពុជាបានរៀបចំឯកសារសំរាប់ ក្រុមហ៊ុន / សហគ្រាស បំពេញដើម្បីចូលរួមពិគ្រោះថ្លៃ។ ឯកសារពិគ្រោះថ្លៃ មានដាក់លក់នៅអង្គភាពលទ្ធកម្មដែលមានអាសយដ្ឋានៈ ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញចាប់ពីថ្ងៃទី ០៤ ខែ មីនា ឆ្នាំ២០២០ តទៅរៀងរាល់ម៉ោងធ្វើការ ( ទូរស័ព្ទទាក់ទងៈ 023 766007 និង Website: www.edc.com.kh ) ។

ឯកសារពិគ្រោះថ្លៃដែលបានបំពេញរួចត្រូវប្រគល់ជូនអង្គភាពលទ្ធកម្មយ៉ាងយូរបំផុតត្រឹមថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០២០ វេលាម៉ោង ១១ : ០០ នាទី ។

ការបើកសំណើពិគ្រោះថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្មតាមអាសយដ្ឋានខាងលើនាថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០២០ វេលាម៉ោង ១៥:៣០ ។

ក្រុមហ៊ុន / សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬ មានប្រភពតែមួយអាចដាក់សំណើពិគ្រោះថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/ សហគ្រាស ដែលមានបំណងចូលរួមពិគ្រោះថ្លៃសូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មដើម្បីទិញឯកសារពិគ្រោះថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ។

ថ្ងៃ ៨កើត ខែផល្គុន ឆ្នាំកុរ ឯកស័កព.ស២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២០
**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

ហង់_ទូច

ចម្លងជូនៈ
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ